11

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងហេតុ

**ប្រវត្តិ:** យោងតាមគោលនយោបាយកំនែទំរង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ក៏ដូចជាយោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រឹត្យលេខ ជស/ រកត/ ១២៩៧ / ២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

ក្រសួងសុខាភិបាលបានរៀបចំធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យបីគឺ :

-ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

-ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

-ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម

នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ព្រះរាជក្រឹត្យទាំងបីនេះបានឆ្លងការប្រជុំអន្តរក្រសួងមួយ ដែលត្រូវបានប្រារព្ធធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម **ណា ឥទាន់** ហើយក្រសួងសុខាភិបាលបានកែសំរួលខ្លឹមសារព្រះរាជក្រឹត្យទាំងបីនេះដូចមានសេចក្តីព្រាងជូនភ្ជាប់មកជាមួយនេះ ។

## I. <u>គោលបំណងនៃព្រះរាជក្រឹត្យ</u>

គោលបំណងនៃការរៀបចំព្រះរាជក្រឹត្យទាំង បី នេះគឺដើម្បីរៀបចំក្របខ័ណ្ឌទៅតាមមុខជំនាញដោយប្រមូលផ្តុំមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិ ឬ ការបណ្តុះបណ្តាលដូចគ្នាហើយមានឧបនិស្ស័យកាន់ដំណែងដូចគ្នា ឬ ប្រភេទមុខដំណែងដូចគ្នា ក្នុងអាជីពរបស់ខ្លួន ។

ការរៀបចំក្របខ័ណ្ឌដោយឡែកនេះគឺសំដៅបង្កើនគុណភាពសមត្ថភាព និងការទទួលខុសត្រូវនៃការបំពេញមុខងាររបស់មន្ត្រីរាជការទាំងឡាយក្នុងក្របខ័ណ្ឌ ។ ការរៀបចំមន្ត្រីរាជការជាក្របខ័ណ្ឌដែលបែង ចែកជា ៤ ប្រភេទគឺ (ក.ខ.គ និង ឃ ) ដែលមានឋានានុក្រមនៃឋានន្តរស័ក្តិ និងបែងចែកជាថ្នាក់ៗសំរួលដល់ការងារគ្រប់គ្រងជ្រើសរើសបណ្តុះបណ្តាល តែងតាំង និងផ្តល់លាភការមួយសមស្រប ស្មើភាពគ្នាសំរាប់មន្ត្រីរាជការ ។

## II. ខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងព្រះរាជក្រឹត្យទាំងនេះ :

- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់មាន ១០ជំពូក និង ២៣ មាត្រា
- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមមាន ១០ជំពូក និង ២១ មាត្រា
- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមមាន ១០ជំពូក និង ២០ មាត្រា

ព្រះរាជក្រឹត្យទាំង បី ខាងនេះបានកំណត់អត្ថន័យ និងខ្លឹមសារលើវិសាលភាព នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ មធ្យម បឋម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ។

### ជំពូកទី I. បទប្បញ្ញត្តិទូទៅ

ព្រះរាជក្រឹត្យទាំងនេះបានកំណត់អំពីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសសុខាភិបាល កំរិតឧត្តម . មធ្យម . បឋម បំរើការងារក្នុងវិស័យសុខាភិបាលតាមអង្គភាពថ្នាក់កណ្តាល និង ខេត្ត-ក្រុង និងគ្រឹះស្ថានសាធារណៈ របស់ក្រសួងស្ថាប័ននានា លើកលែងតែមន្ត្រីសកម្មស្ថិតក្នុងក្របខ័ណ្ឌក្រសួងការពារជាតិ និងនគរបាលជាតិ ។

### ជំពូកទី II. ឋានន្តរស័ក្តិ និង មុខតំណែង

ជំពូកនេះបានកំណត់ពីឋានន្តរស័ក្តិនិងមុខតំណែងរបស់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់.មធ្យម.បឋម។

### ជំពូកទី III. ការជ្រើសរើស

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់.មធ្យម.បឋម គឺត្រូវឆ្លងកាត់ការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត ឬ មន្ត្រីរាជការ ។

### ជំពូកទី IV. ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បងនិងការតាំងស៊ប់

ការបណ្តុះបណ្តាលដំបូងគឺក្រសួងសុខាភិបាលជាអ្នកទទួលបណ្តុះបណ្តាល ។ ~~ចំណែកឯកម្មសិក្សាសាកល្បង និងការតាំងស៊ប់~~ កំណត់ដោយ~~ប្រកាសរបស់ក្រសួងសុខាភិបាល~~ ។

### ជំពូកទី V. ការតែងតាំង

ការតែងតាំងត្រូវធ្វើឡើងអោយស្របទៅនឹងមាត្រាដែលបានចែងក្នុងព្រះរាជក្រឹត្យទាំងនេះ និង ព្រះរាជក្រមដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

**ជំពូកទី VI. ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម**

ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម គឺធ្វើឡើងតាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

**ជំពូកទី VII. ការតំឡើងថ្នាក់និងការតំឡើងឋានន្តរស័ក្តិ**

នៅក្នុងជំពូកនេះការតំឡើងថ្នាក់ និងឋានន្តរស័ក្តិគឺធ្វើឡើងដោយផ្អែកទៅលើលក្ខណៈសម្បត្តិរបស់ផ្ទាល់ខ្លួននិងលក្ខខ័ណ្ឌបណ្តុះបណ្តាល ដោយមានសញ្ញាប័ត្រជាមូលដ្ឋានពិសេសគឺផ្អែកទៅលើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**ជំពូកទី VIII. បទប្បញ្ញត្តិដោយឡែក**

ជំពូកនេះគឺបញ្ជាក់ពីការលើកទឹកចិត្ត និងតំឡើងថ្នាក់ជូន មន្ត្រីរាជការដែលមានស្នាដៃ និង សមត្ថភាព ។

**ជំពូកទី IX. អន្តរប្បញ្ញត្តិ**

ជំពូកនេះបានបញ្ជាក់ពីចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីរាជការសុខាភិបាលជាន់ខ្ពស់ មធ្យម និងបឋម គឺធ្វើឡើងតាមរយៈ សមាហរណកម្មមន្ត្រីរាជការ ។ ចំណែកឯមុខតំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយគឺនៅដដែលលើកលែងតែមានការចាំ បាច់របស់ក្រសួងទើបមានការផ្លាស់ប្តូរ ។

**ជំពូកទី X. អវសានប្បញ្ញត្តិ**

បានកំណត់ជារួមព្រះរាជក្រឹត្យទាំងបីនេះបានតាក់តែង និរាករណ៍ចំពោះបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យទាំងបីនេះ ។

ជារួមក្រសួងសុខាភិបាលបានតាក់តែងព្រះរាជក្រឹត្យទាំងនេះឡើងក្នុងគោលបំណងចូលរួមចំណែកក្នុងការកសាងនីតិរដ្ឋនិងស្របតាមទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

អាស្រ័យហេតុនេះសូម សម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាប និង ពិនិត្យអនុម័តដោយអនុគ្រោះ ។

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០២